**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ០៩ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការគ្រប់គ្រងសន្តិសុខអាកាសចរណ៍ស៊ីវិលនៅក្នុងព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២៣/០២០ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៨/០០៣ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការគ្រប់គ្រងសន្តិសុខអាកាសចរណ៍ស៊ីវិលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃអាកាសចរណ៍ស៊ីវិល ការពារសន្តិសុខ និងសុវត្ថិភាពដល់អ្នកដំណើរ ក្រុមអាកាសយានិក បុគ្គលិកបម្រើការងារលើផ្ទៃដី សាធារណជនទូទៅ អាកាសយាន អាកាសយានដ្ឋានអន្តរជាតិ អាកាសយានដ្ឋានមូលដ្ឋាន និងបបនីយកណ្ឌអាកាសយានដ្ឋាន ព្រមទាំងប្រឆាំងនឹងអំពើរំលោភបំពានច្បាប់នៅលើផ្ទៃដីដែលពាក់ព័ន្ធជាមួយនឹងសកម្មភាពអាកាសចរណ៍ស៊ីវិល និងពេលកំពុងហោះហើរ។ ៚

**មាត្រា២ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តលើការគ្រប់គ្រងសន្តិសុខអាកាសយានដ្ឋាន ក្រុមហ៊ុនអាកាសចរណ៍ ក្រុមហ៊ុនគ្រប់គ្រងសេវាកម្មចរាចរដែនអាកាស និងក្រុមហ៊ុនផ្សេងៗទៀតដែលផ្តល់សេវាកម្មពាក់ព័ន្ធនឹងវិស័យអាកាសចរណ៍ស៊ីវិល នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១-កម្មវិធីជាតិសន្តិសុខអាកាសចរណ៍ស៊ីវិល សំដៅដល់គោលការណ៍ណែនាំដែលមានលក្ខណៈជាបទប្បញ្ញត្តិ ស្តង់ដា វិធានការ នីតិវិធី និងការអនុវត្ត ដើម្បីគ្រប់គ្រងនិងការពារសន្តិសុខអាកាសចរណ៍ស៊ីវិលធានាសុវត្ថិភាព និរន្តរភាព និងប្រសិទ្ធភាពអាកាសចរណ៍ស៊ីវិល។

២-កម្មវិធីជាតិត្រួតពិនិត្យគុណភាពសន្តិសុខអាកាសចរណ៍ស៊ីវិល សំដៅដល់គោលការណ៍ណែនាំក្នុងការរៀបចំ តាមដាន ត្រួតពិនិត្យគ្រប់អាជ្ញាធរមានសមត្ថកិច្ចនានា ដើម្បីធានាការអនុវត្តគោលនយោបាយសន្តិសុខនិងស្តង់ដាឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីទទួលបានលទ្ធផលប្រកបដោយប្រសិទ្ធភាពនិងរក្សាបានភាពប្រក្រតី។

៣-កម្មវិធីបណ្តុះបណ្តាលសន្តិសុខអាកាសចរណ៍ស៊ីវិល សំដៅដល់គោលការណ៍ណែនាំក្នុងការបណ្តុះបណ្តាលត្រឹមត្រូវសម្រាប់អនុវត្តការងារនិងយល់ដឹងអំពីបញ្ហាសន្តិសុខ ជូនដល់កងកម្លាំងមានសមត្ថកិច្ចដែលអនុវត្តកម្មវិធីជាតិសន្តិសុខអាកាសចរណ៍ស៊ីវិល។

៤-កម្មវិធីជាតិសម្របសម្រួលដឹកជញ្ជូនផ្លូវអាកាស សំដៅដល់គោលការណ៍ណែនាំក្នុងការកាត់បន្ថយការកកស្ទះ ការបង្កើនប្រសិទ្ធភាព និងការកែលម្អសេវាអតិថិជនឱ្យមានភាពរលូន ឆាប់រហ័ស ស្របតាមវិធាននៃការការពារសន្តិសុខនិងសុវត្ថិភាពអាកាសចរណ៍ស៊ីវិលអន្តរជាតិ ប្រឆាំងការប្រព្រឹត្តអំពើរំលោភបំពានខុសច្បាប់។

៥-កម្មវិធីសន្តិសុខប្រតិបត្តិករ សំដៅដល់កម្មវិធីសន្តិសុខក្រុមហ៊ុនអាកាសចរណ៍ កម្មវិធីសន្តិសុខអាកាសយានដ្ឋានអន្តរជាតិ អាកាសយានដ្ឋានមូលដ្ឋាន កម្មវិធីសន្តិសុខក្រុមហ៊ុនគ្រប់គ្រងសេវាកម្មចរាចរដែនអាកាស និងកម្មវិធីសន្តិសុខក្រុមហ៊ុនផ្សេងៗទៀត ដែលផ្តល់សេវាកម្មនៅអាកាសយានដ្ឋាន។

៦-បរិវេណអាកាសយានដ្ឋាន សំដៅដល់ហេដ្ឋារចនាសម្ព័ន្ធ ឧបករណ៍ សម្ភារៈ បរិក្ខារបច្ចេកទេសដែលពាក់ព័ន្ធនឹងប្រតិបត្តិការអាកាសយានដ្ឋាននិងអាកាសយាន ស្របតាមស្តង់ដាបច្ចេកទេស។

## ជំពូកទី២
## គណៈកម្មាធិការជាតិសន្តិសុខអាកាសចរណ៍ស៊ីវិល

**មាត្រា៤ .-**

ត្រូវបានបង្កើត "គណៈកម្មាធិការជាតិសន្តិសុខអាកាសចរណ៍ស៊ីវិល" ដែលសរសេរជាអក្សរកាត់ថា "**គ.ជ.ស.អ.**" ដើម្បីធ្វើជាសេនាធិការឱ្យរាជរដ្ឋាភិបាល លើការដឹកនាំ និងគ្រប់គ្រងការងារសន្តិសុខអាកាសចរណ៍ស៊ីវិលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៥ .-**

**គ.ជ.ស.អ.** មានសមាសភាពដូចខាងក្រោម៖

- ឯកឧត្តមសន្តិបណ្ឌិត **នេត សាវឿន** ឧបនាយករដ្ឋមន្ត្រី ប្រធាន
- ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ឱម យ៉ិនទៀង** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម អនុប្រធាន

| | | |
|---|---|---|
| - ឯកឧត្តម **ម៉ៅ ហាវណ្ណាល់** | រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋាន អាកាសចរណ៍ស៊ីវិល | អនុប្រធានប្រចាំការ |
| - ឯកឧត្តម **ម៉ែន វិបុល** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី | អនុប្រធាន |
| - ឯកឧត្តម **គុណ ញឹម** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីទទួលបន្ទុកជា អគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | អនុប្រធាន |
| - ឯកឧត្តម **ឈាង វណ្ណារិទ្ធ** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| - ឯកឧត្តមសន្តិបណ្ឌិត **គៀត ច័ន្ទថារិទ្ធ** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| - ឯកឧត្តមឧត្តមសេនីយ៍ទោ **រ៉ាត់ ដារ៉ារ័ត្ន** | រដ្ឋលេខាធិការក្រសួងការពារជាតិ | អនុប្រធាន |
| - ឯកឧត្តម **ស៊ាំ កុសល** | រដ្ឋលេខាធិការប្រចាំការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| - ឯកឧត្តមនាយឧត្តមសេនីយ៍ **វង្ស ពិសេន** | អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ | អនុប្រធាន |
| - ឯកឧត្តមនាយឧត្តមសេនីយ៍ **ស ថេត** | អគ្គស្នងការនគរបាលជាតិ | អនុប្រធាន |
| - ឯកឧត្តមនាយឧត្តមសេនីយ៍ **សៅ សុខា** | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | អនុប្រធាន |
| - ឯកឧត្តមនាយឧត្តមសេនីយ៍ **ម៉ៅ សុផាន់** | មេបញ្ជាការកងទ័ពជើងគោក | អនុប្រធាន |
| - ឯកឧត្តម **ឡាំ ហេងហួត** | អនុប្រធានគណៈកម្មាធិការជាតិ គ្រប់គ្រងគ្រោះមហន្តរាយ | សមាជិក |
| - ឯកឧត្តម **ចោង លឹម** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - ឯកឧត្តម **គង់ ច័ន្ទវាសនា** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| - ឯកឧត្តម **ខាន់ វណ្ណៈ** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| - ឯកឧត្តម **ហោ សារុន** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| - ឯកឧត្តម **ធិត្យ ពៅ** | រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋាន អាកាសចរណ៍ស៊ីវិល | សមាជិក |
| - ឯកឧត្តម **ស៊ូ ភិត្យា** | អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋាន អាកាសចរណ៍ស៊ីវិល | សមាជិក |
| - ឯកឧត្តម **សារិន គុណ្ណាភារ** | អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | សមាជិក |
| - ឯកឧត្តមឧត្តមសេនីយ៍ឯក **សុខ វាសនា** | អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ នៃក្រសួងមហាផ្ទៃ | សមាជិក |
| - ឯកឧត្តមឧត្តមសេនីយ៍ឯក **តុប នេត** | អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ | សមាជិក |
| - ឯកឧត្តមឧត្តមសេនីយ៍ឯក **ឌី វិជ្ជា** | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| - ឯកឧត្តមនាយឧត្តមសេនីយ៍ **សឹង សំណាង** | មេបញ្ជាការកងទ័ពជើងអាកាស | សមាជិក |
| - ឯកឧត្តមនាយឧត្តមនាវី **ទៀ វិញ** | មេបញ្ជាការកងទ័ពជើងទឹក | សមាជិក |
| - ឧត្តមសេនីយ៍ឯក **ហែម ថា** | មេបញ្ជាការកងពលតូចលេខ៧០ | សមាជិក |
| - ឯកឧត្តម **ឆាន់ ចាន់ធុច** | ប្រធាននាយកដ្ឋានសន្តិសុខអាកាសចរណ៍ស៊ីវិល នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | សមាជិក |

- ឯកឧត្តម **សៅ ចន្ថាវុធ** នាយកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សមាជិក
- ឯកឧត្តម **ម៉ឺន រដ្ឋា** នាយកអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សមាជិក
- ឯកឧត្តម **ខ៊ាន់ ណូរ៉ាក់** នាយកអាកាសយានដ្ឋានអន្តរជាតិព្រះសីហនុ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សមាជិក
- លោក **ម៉ៅ កែវពេជ្រច័ន្ទមុន្នី** នាយកអាកាសយានដ្ឋានអន្តរជាតិតារាសាគរ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សមាជិក
- ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី ខេត្តដែលមានអាកាសយានដ្ឋាន សមាជិក។

សមាសភាព **គ.ជ.ស.អ.** អាចត្រូវបានកែសម្រួល ឬបំពេញបន្ថែមដោយអនុក្រឹត្យ។

**មាត្រា៦ .-**

ក្នុងការអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួន **គ.ជ.ស.អ.** មានអង្គភាពដូចខាងក្រោម ដើម្បីជាសេនាធិការៈ
- អគ្គនាយកដ្ឋានបច្ចេកទេសនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល
- នាយកដ្ឋានសន្តិសុខអាកាសចរណ៍ស៊ីវិល
- គណៈកម្មការសន្តិសុខអាកាសយានដ្ឋានអន្តរជាតិ
- គណៈកម្មការសន្តិសុខអាកាសយានដ្ឋានមូលដ្ឋាន។

អង្គភាពដូចមានកំណត់ខាងលើនេះ បំពេញមុខងារ និងភារកិច្ចរបស់ខ្លួន ស្របតាមការកំណត់នៅក្នុងអនុក្រឹត្យនេះ បន្ថែមលើមុខងារ និងភារកិច្ចដែលបានកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៧ .-**

**គ.ជ.ស.អ.** មានភារកិច្ចដូចខាងក្រោមៈ
- ដឹកនាំ និងគ្រប់គ្រងការងារសន្តិសុខអាកាសចរណ៍ស៊ីវិលនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ដឹកនាំ សម្របសម្រួល ក៏ដូចជា ដាក់ចេញនូវវិធានការចាំបាច់នានា ដើម្បីធានាបាននូវសណ្តាប់ធ្នាប់ របៀបរៀបរយ និងបរិយាកាសល្អប្រសើរនៅអាកាសយានដ្ឋាន
- រៀបចំកម្មវិធីជាតិសន្តិសុខអាកាសចរណ៍ស៊ីវិល កម្មវិធីជាតិត្រួតពិនិត្យគុណភាពសន្តិសុខអាកាសចរណ៍ស៊ីវិល កម្មវិធីជាតិបណ្តុះបណ្តាលសន្តិសុខអាកាសចរណ៍ស៊ីវិល និងកម្មវិធីជាតិសម្របសម្រួលការដឹកជញ្ជូនផ្លូវអាកាស ដើម្បីដាក់ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច
- ពិនិត្យលើគោលនយោបាយជាតិ សន្ធិសញ្ញា អនុសញ្ញា ពិធីសារ អនុស្សរណៈនៃការយោគយល់គ្នា និងកិច្ចព្រមព្រៀងអន្តរជាតិនានាស្តីពីសន្តិសុខអាកាសចរណ៍ស៊ីវិល ដើម្បីដាក់ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច
- បែងចែក និងប្រគល់ភារកិច្ចដល់មន្ត្រីនិងកងកម្លាំងក្រោមឱវាទ និងក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ដើម្បីអនុវត្តតាមកម្មវិធីជាតិសន្តិសុខអាកាសចរណ៍ស៊ីវិល គោលនយោបាយជាតិ សន្ធិសញ្ញា អនុសញ្ញា ពិធីសារ អនុស្សរណៈនៃការយោគយល់គ្នា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសន្តិសុខអាកាសចរណ៍ស៊ីវិល ព្រមទាំងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ៚

- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំលើការអនុវត្តកម្មវិធីជាតិអាកាសចរណ៍ស៊ីវិល គោលនយោបាយជាតិ សន្ធិសញ្ញា អនុសញ្ញា ពិធីសារ អនុស្សរណៈនៃការយោគយល់គ្នា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសន្តិសុខអាកាសចរណ៍ស៊ីវិល ព្រមទាំងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា
- ពិនិត្យ និងសម្រេចលើការគ្រប់គ្រងតំបន់ពិសេស ក្នុងបរិវេណអាកាសយានដ្ឋាននៃព្រះរាជាណាចក្រកម្ពុជា
- ពិនិត្យ និងសម្រេចលើបទប្បញ្ញត្តិស្តីពីការផ្តល់បណ្ណចេញ-ចូលអាកាសយានដ្ឋានសម្រាប់យានយន្ត និងសម្រាប់មន្ត្រីរាជការ និងបុគ្គលិកនៃក្រសួង ស្ថាប័ន អង្គទូត អគ្គកុងស៊ុល អង្គការនានា និងក្រុមហ៊ុនឯកជន ដែលមានភារកិច្ចចាំបាច់
- បូកសរុបសភាពការណ៍និងសកម្មភាពការងារសន្តិសុខអាកាសចរណ៍ស៊ីវិល ដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។

**មាត្រា៨ .-**

**គ.ជ.ស.អ.** ធ្វើការប្រជុំមួយឆមាសម្តង តាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីចាំបាច់ ប្រធាន **គ.ជ.ស.អ.** អាចកោះអញ្ជើញប្រជុំវិសាមញ្ញបាន។ អនុប្រធាន និងសមាជិក **គ.ជ.ស.អ.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន ឬមានធុរៈ ប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធានណាម្នាក់ ដើម្បីដឹកនាំកិច្ចប្រជុំជំនួស។

**មាត្រា៩ .-**

**គ.ជ.ស.អ.** អាចអញ្ជើញតំណាងក្រសួង ឬស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញ អ្នកបច្ចេកទេស ឬផ្នែកឯកជន ចូលរួមប្រជុំ ពិគ្រោះយោបល់ និងស្រាវជ្រាវលើរាល់បញ្ហាទាំងឡាយទាក់ទងនឹងក្របខ័ណ្ឌការងាររបស់ខ្លួន តាមការចាំបាច់។

**មាត្រា១០ .-**

**គ.ជ.ស.អ.** អាចមានទីប្រឹក្សាបច្ចេកទេស និងអ្នកជំនាញការជាតិ ឬអន្តរជាតិមួយចំនួន តាមការចាំបាច់។

**មាត្រា១១ .-**

**គ.ជ.ស.អ.** មានសិទ្ធិប្រើត្រារបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ក្នុងកិច្ចដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៣

## អគ្គនាយកដ្ឋានបច្ចេកទេសនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល

**មាត្រា១២ .-**

**គ.ជ.ស.អ.** មានអគ្គនាយកដ្ឋានបច្ចេកទេសនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ជាសេនាធិការលើការងារបច្ចេកទេសអាកាសចរណ៍ស៊ីវិល ដែលមានភារកិច្ចបន្ថែមដូចខាងក្រោម៖

- រៀបចំ ចងក្រង និងកែសម្រួលលើកម្មវិធីជាតិសន្តិសុខអាកាសចរណ៍ស៊ីវិល កម្មវិធីជាតិត្រួតពិនិត្យគុណភាពសន្តិសុខអាកាសចរណ៍ស៊ីវិល កម្មវិធីជាតិបណ្តុះបណ្តាលសន្តិសុខអាកាសចរណ៍ស៊ីវិល និងកម្មវិធីជាតិសម្របសម្រួលដឹកជញ្ជូនផ្លូវអាកាស ៸៸៸

- ពិនិត្យកម្មវិធីសន្តិសុខប្រតិបត្តិករមុននឹងស្នើសុំការយល់ព្រមពីប្រធាន **គ.ជ.ស.អ.**
- សម្របសម្រួលជាមួយអង្គភាពអាកាសចរណ៍ស៊ីវិលអន្តរជាតិ លើការងារសន្តិសុខអាកាសចរណ៍ស៊ីវិល
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រធាន **គ.ជ.ស.អ.**។

## ជំពូកទី៤
## លេខាធិការដ្ឋាននៃ គ.ជ.ស.អ.

### មាត្រា១៣ .-

**គ.ជ.ស.អ.** ប្រើប្រាស់នាយកដ្ឋានសន្តិសុខអាកាសចរណ៍ស៊ីវិលនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ជាលេខាធិការដ្ឋាន ដើម្បីធ្វើជាសេនាធិការផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ សម្រាប់គាំទ្រដល់កិច្ចដំណើរការការងាររបស់ខ្លួន និងអនុវត្តមុខងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់ប្រធាន **គ.ជ.ស.អ.**។

សមាសភាព ការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាននៃ **គ.ជ.ស.អ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.ស.អ.**។

## ជំពូកទី៥
## គណៈកម្មការសន្តិសុខអាកាសយានដ្ឋានអន្តរជាតិ

### មាត្រា១៤ .-

**គ.ជ.ស.អ.** មាន គណៈកម្មការសន្តិសុខអាកាសយានដ្ឋានអន្តរជាតិ សរសេរជាអក្សរកាត់ថា **គ.ស.អ.អ.** ជាអង្គភាពប្រតិបត្តិការស្ថិតក្រោមការដឹកនាំ និងគ្រប់គ្រងផ្ទាល់របស់ខ្លួន និងមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| - នាយកអាកាសយានដ្ឋានអន្តរជាតិ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | | ប្រធាន |
| - អគ្គស្នងការរងនគរបាលជាតិ | ១រូប | អនុប្រធាន |
| - តំណាងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ នៃក្រសួងមហាផ្ទៃ ប្រចាំការនៅអាកាសយានដ្ឋានអន្តរជាតិ | ១រូប | អនុប្រធាន |
| - តំណាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រចាំការនៅអាកាសយានដ្ឋានអន្តរជាតិ | ១រូប | អនុប្រធាន |
| - តំណាងនាយកដ្ឋានសន្តិសុខអាកាសចរណ៍ស៊ីវិល នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | ១រូប | អនុប្រធាន |
| - តំណាងសាលារាជធានី ខេត្ត ដែលមានអាកាសយានដ្ឋានអន្តរជាតិ | ១រូប | អនុប្រធាន |
| - តំណាងបញ្ជាការដ្ឋានកងទ័ពជើងអាកាស | ១រូប | អនុប្រធាន |
| - តំណាងកងពលតូចលេខ៧០ | ១រូប | អនុប្រធាន |
| - ប្រធានការិយាល័យសន្តិសុខអាកាសយានដ្ឋានអន្តរជាតិ | | អនុប្រធានប្រចាំការ |
| - តំណាងបញ្ជាការដ្ឋានជាតិកម្លាំងពិសេសប្រឆាំងភេរវកម្ម | ១រូប | សមាជិក |
| - តំណាងបញ្ជាការដ្ឋានកងទ័ពជើងទឹក | ១រូប | សមាជិក |
| - តំណាងបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស | ១រូប | សមាជិក |
| - តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំការនៅអាកាសយានដ្ឋានអន្តរជាតិ | ១រូប | សមាជិក |

- តំណាងអង្គភាពតម្រួតបទបញ្ជានៃអគ្គស្នងការដ្ឋាននគរបាលជាតិ
ប្រចាំការនៅអាកាសយានដ្ឋានអន្តរជាតិ ១រូប សមាជិក
- តំណាងក្រុមហ៊ុនអាកាសចរណ៍ជាតិ ១រូប សមាជិក
- តំណាងក្រុមហ៊ុនគ្រប់គ្រងសេវាកម្មចរាចរដែនអាកាស ១រូប សមាជិក
- តំណាងប្រតិបត្តិករអាកាសយានដ្ឋាន ១រូប សមាជិក។

**គ.ស.អ.អ.** អាចមានសមាសភាពបន្ថែមផ្សេងទៀតជាអនុប្រធាន ឬសមាជិក តាមការចាំបាច់។ សមាសភាពជាក់ស្តែង និងសមាសភាពបន្ថែមនៃ **គ.ស.អ.អ.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.ស.អ.**។

**មាត្រា១៥.-**

**គ.ស.អ.អ.** មានភារកិច្ចដូចខាងក្រោម៖

- ដឹកនាំនិងគ្រប់គ្រងលើការងារសន្តិសុខអាកាសចរណ៍ស៊ីវិលទាំងនៅក្នុង និងនៅជុំវិញអាកាសយានដ្ឋានអន្តរជាតិ
- អនុវត្តនិងសម្របសម្រួលលើការងារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ទាំងនៅក្នុង និងនៅជុំវិញអាកាសយានដ្ឋានអន្តរជាតិ ឱ្យស្របតាមកម្មវិធីជាតិសន្តិសុខអាកាសចរណ៍ស៊ីវិល និងកម្មវិធីសន្តិសុខប្រតិបត្តិករអាកាសយានដ្ឋាន
- ត្រួតពិនិត្យនិងតាមដានលើការអនុវត្តកម្មវិធីសន្តិសុខរបស់ប្រតិបត្តិករអាកាសយានដ្ឋាន រួមទាំងវិធានការសន្តិសុខពិសេសៗ ដែលស្នើឡើងដោយប្រតិបត្តិករ
- ផ្សព្វផ្សាយកម្មវិធីជាតិសន្តិសុខអាកាសចរណ៍ស៊ីវិល កម្មវិធីសន្តិសុខប្រតិបត្តិករអាកាសយានដ្ឋាន និងកម្មវិធីសន្តិសុខពាក់ព័ន្ធផ្សេងៗ ដល់បណ្តាក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដើម្បីអនុវត្ត
- ធានារក្សាបាននូវវិធានការអប្បបរមានិងបទដ្ឋាននានាដើម្បីឆ្លើយតបនឹងការគំរាមកំហែង និងត្រួតពិនិត្យជាប្រចាំនូវវិធានការសន្តិសុខដែលអាចធានាបានទាំងស្ថានភាពធម្មតា ទាំងស្ថានភាពអាសន្ន
- សហការជាមួយប្រតិបត្តិករអាកាសយានដ្ឋាន ដើម្បីកំណត់ផែនទីតំបន់ធ្វើសកម្មភាព និងតំបន់ហាមឃាត់នៅក្នុងអាកាសយានដ្ឋានអន្តរជាតិ
- កំណត់ផែនទីគោលដៅសន្តិសុខ ចាត់តាំងកងកម្លាំងឈរជើង និងពិនិត្យលើការបំពាក់ឧបករណ៍សម្ភារៈឱ្យគ្រប់គ្រាន់សម្រាប់បម្រើឱ្យការងារសន្តិសុខនៅក្នុងបរិវេណអាកាសយានដ្ឋានអន្តរជាតិ
- សហការអនុវត្តកម្មវិធីត្រួតពិនិត្យគុណភាពសន្តិសុខនៅអាកាសយានដ្ឋានអន្តរជាតិ រួមមានការវាយតម្លៃ សវនកម្ម អធិការកិច្ច ការសាកល្បង និងការអង្កេតតាមកម្មវិធី ព្រមទាំងការអង្កេតក្នុងករណីចាំបាច់
- សហការនិងចូលរួមផ្តល់យោបល់លើការបញ្ចូលវិធានការសន្តិសុខទៅក្នុងគម្រោងកែលម្អ និងអភិវឌ្ឍអាកាសយានដ្ឋានអន្តរជាតិ
- រៀបចំឱ្យមានសកម្មភាពល្បាត ដើម្បីទប់ស្កាត់អំពើភេរវកម្មនិងសកម្មភាពល្មើសច្បាប់ផ្សេងទៀត
- ត្រូវចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន **គ.ជ.ស.អ.**
- រៀបចំកិច្ចប្រជុំយ៉ាងតិចមួយខែម្តង និងក្នុងករណីចាំបាច់ត្រូវកោះប្រជុំវិសាមញ្ញ

- បូកសរុប និងរាយការណ៍អំពីសភាពការណ៍ និងសកម្មភាពការងារនៅអាកាសយានដ្ឋានអន្តរជាតិ ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ ជូនប្រធាន **គ.ជ.ស.អ.** ដើម្បីជ្រាប និងផ្តល់ការណែនាំ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធាន **គ.ជ.ស.អ.**។

**មាត្រា១៦ .-**

**គ.ស.អ.អ.** មានសិទ្ធិប្រើត្រារបស់អាកាសយានដ្ឋានអន្តរជាតិសាមី សម្រាប់កិច្ចដំណើរការការងាររបស់ខ្លួន។

**គ.ស.អ.អ.** មានទីតាំងនៅអាកាសយានដ្ឋានអន្តរជាតិសាមី។

## ជំពូកទី៦
## គណៈកម្មការសន្តិសុខអាកាសយានដ្ឋានមូលដ្ឋាន

**មាត្រា១៧ .-**

**គ.ជ.ស.អ.** មាន គណៈកម្មការសន្តិសុខអាកាសយានដ្ឋានមូលដ្ឋាន សរសេរជាអក្សរកាត់ **គ.ស.អ.ម.** ជាអង្គភាពស្ថិតក្រោមការដឹកនាំនិងគ្រប់គ្រងផ្ទាល់របស់ខ្លួននិងមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| - នាយកអាកាសយានដ្ឋានមូលដ្ឋាននៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | | ប្រធាន |
| - តំណាងសាលាខេត្តដែលមានអាកាសយានដ្ឋាន | ១រូប | អនុប្រធាន |
| - ប្រធានសន្តិសុខអាកាសយានដ្ឋានមូលដ្ឋាននីមួយៗ | | អនុប្រធានប្រចាំការ |
| - តំណាងស្នងការដ្ឋាននគរបាលខេត្តដែលមានអាកាសយានដ្ឋាន | ១រូប | សមាជិក |
| - តំណាងបញ្ជាការដ្ឋានកងទ័ពជើងអាកាស | ១រូប | សមាជិក |
| - តំណាងបញ្ជាការដ្ឋានយោធភូមិភាគ | ១រូប | សមាជិក |
| - តំណាងកងរាជអាវុធហត្ថខេត្តដែលមានអាកាសយានដ្ឋាន | ១រូប | សមាជិក |
| - តំណាងតំបន់ប្រតិបត្តិការសឹករងខេត្តដែលមានអាកាសយានដ្ឋាន | ១រូប | សមាជិក |
| - តំណាងក្រុមហ៊ុនគ្រប់គ្រងសេវាកម្មចរាចរដែនអាកាស | ១រូប | សមាជិក។ |

**គ.ស.អ.ម.** អាចមានសមាសភាពបន្ថែមផ្សេងទៀតជាអនុប្រធាន ឬសមាជិក តាមការចាំបាច់។ សមាសភាពជាក់ស្តែង និងសមាសភាពបន្ថែមនៃ **គ.ស.អ.ម.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.ស.អ.**។

**មាត្រា១៨ .-**

**គ.ស.អ.ម.** មានភារកិច្ចដូចខាងក្រោម៖

- ដឹកនាំនិងគ្រប់គ្រងលើការងារសន្តិសុខអាកាសចរណ៍ស៊ីវិលទាំងនៅក្នុង និងនៅជុំវិញអាកាសយានដ្ឋានមូលដ្ឋាន
- រៀបចំ ចងក្រង អនុវត្ត និងកែសម្រួលសេចក្តីព្រាងកម្មវិធីសន្តិសុខអាកាសយានដ្ឋានមូលដ្ឋាន
- អនុវត្តនិងសម្របសម្រួលលើការងារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ទាំងនៅក្នុង និងនៅជុំវិញអាកាសយានដ្ឋានមូលដ្ឋាន ឱ្យស្របតាមកម្មវិធីជាតិសន្តិសុខអាកាសចរណ៍ស៊ីវិល និងកម្មវិធីសន្តិសុខអាកាសយានដ្ឋានមូលដ្ឋាន

- ផ្សព្វផ្សាយកម្មវិធីជាតិសន្តិសុខអាកាសចរណ៍ស៊ីវិល និងកម្មវិធីសន្តិសុខអាកាសយានដ្ឋានមូលដ្ឋាន ដល់បណ្តាក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ ដើម្បីអនុវត្ត
- ធានារក្សាបាននូវវិធានការអប្បបរមានិងបទដ្ឋាននានាដើម្បីឆ្លើយតបទៅនឹងការគំរាមកំហែង និងត្រួតពិនិត្យជាប្រចាំនូវវិធានការសន្តិសុខទាំងស្ថានភាពធម្មតា ទាំងស្ថានភាពអាសន្ន
- កំណត់ដែនទីតំបន់ហាមឃាត់ តំបន់ធ្វើសកម្មភាព និងចាត់តាំងកងកម្លាំងឈរជើងនៅក្នុងបរិវេណអាកាសយានដ្ឋានមូលដ្ឋាន
- សហការនិងចូលរួមផ្តល់យោបល់លើការបញ្ចូលវិធានការសន្តិសុខទៅក្នុងគម្រោងអភិវឌ្ឍន៍អាកាសយានដ្ឋានមូលដ្ឋាន
- ត្រូវចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន **គ.ជ.ស.អ.**
- រៀបចំឱ្យមានកិច្ចប្រជុំជាទៀងទាត់រៀងរាល់ខែ និងតាមការចាំបាច់
- បូកសរុប និងរាយការណ៍អំពីសភាពការណ៍ និងសកម្មភាពការងារនៅអាកាសយានដ្ឋានមូលដ្ឋាន ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ ជូនប្រធាន **គ.ជ.ស.អ.** ដើម្បីជ្រាប និងផ្តល់ការណែនាំ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធាន **គ.ជ.ស.អ.**។

## ជំពូកទី៧
## សមត្ថកិច្ចរដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា១៩ .-**

អភិបាលនៃគណៈអភិបាលរាជធានី ខេត្តសាមី ដែលមានអាកាសយានដ្ឋានអន្តរជាតិ និង/ឬ អាកាសយានដ្ឋានមូលដ្ឋាន មានភារកិច្ចដូចខាងក្រោម៖

- អនុវត្តច្បាប់ និងបទបញ្ញារបស់រាជរដ្ឋាភិបាល ព្រមទាំងបទបញ្ញារបស់ **គ.ជ.ស.អ.** ស្តីពីសកម្មភាពការងារដែលពាក់ព័ន្ធនឹងសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈនៅតំបន់ជុំវិញអាកាសយានដ្ឋានអន្តរជាតិ និងអាកាសយានដ្ឋានមូលដ្ឋាន
- បង្ការ ទប់ស្កាត់ និងលុបបំបាត់នូវក្រុម និងសំណង់អនាធិបតេយ្យនៅជាប់ជុំវិញអាកាសយានដ្ឋានអន្តរជាតិ និងអាកាសយានដ្ឋានមូលដ្ឋាន ដែលស្ថិតក្រោមការគ្រប់គ្រងនិងសមត្ថកិច្ចរបស់ខ្លួន
- ធានានិងការពារសន្តិសុខ និងសុវត្ថិភាពដល់អាកាសយាន អ្នកដំណើរ និងអីវ៉ាន់ ក្នុងករណីចុះចតបន្ទាន់ ឬមានឧប្បត្តិហេតុ ស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

## ជំពូកទី៨
## ប្រភពធនធាន និងថវិកានៃ គ.ជ.ស.អ.

**មាត្រា២០ .-**

ប្រភពធនធាន និងថវិកាសម្រាប់ដំណើរការរបស់ **គ.ជ.ស.អ.** រួមមាន៖

- ថវិកាជាតិជាកញ្ចប់ថវិកាដោយឡែក នៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល
- ចំណូលបានមកពីការប្រមូលកម្រៃសេវាកម្មសន្តិសុខ
- ប្រភពស្របច្បាប់ផ្សេងទៀត។ ៚

## ជំពូកទី៩
## យន្តការអន្តរាគមន៍

**មាត្រា២១ .-**

កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួង និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ដែលមានទីតាំងនៅជិតអាកាសយានដ្ឋានអន្តរជាតិ និងអាកាសយានដ្ឋានមូលដ្ឋាន ត្រូវចេញធ្វើអន្តរាគមន៍ជាបន្ទាន់តាមតួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គភាពសាមី ក្នុងពេលដែលមានសំណូមពរពីប្រធាន **គ.ជ.ស.អ.**។

ក្នុងករណីមានកើតជំងឺឆ្លងរាលដាលក្នុងផ្ទៃប្រទេស និងអន្តរជាតិ ឬមានគ្រោះមហន្តរាយធ្ងន់ធ្ងរកើតឡើង រាជរដ្ឋាភិបាលត្រូវចេញបទបញ្ជាឱ្យមន្ត្រី ភ្នាក់ងារ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទនៃក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ចេញធ្វើអន្តរាគមន៍បំពេញបេសកកម្មនៅអាកាសយានដ្ឋានអន្តរជាតិ និងអាកាសយានដ្ឋានមូលដ្ឋាន តាមករណីជាក់ស្តែងនីមួយៗ។

## ជំពូកទី១០
## ទណ្ឌកម្ម

**មាត្រា២២ .-**

មន្ត្រី ភ្នាក់ងារ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទដែលមានសមត្ថកិច្ចនៃក្រសួង ស្ថាប័ន និងអង្គភាព ដែលបានចាត់បញ្ជូនមកឱ្យប្រចាំការ ឬបំពេញបេសកកម្មការងារនៅក្នុងអាកាសយានដ្ឋានអន្តរជាតិ និងអាកាសយានដ្ឋានមូលដ្ឋាន ដែលបានឆ្លៀតប្រើប្រាស់តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ខ្លួនបង្កឱ្យមានការលំបាកដល់អ្នកដំណើរ និងការឆ្លងកាត់ទំនិញគ្រប់ប្រភេទនៃប្រតិបត្តិការអាកាសយានរបស់ក្រុមហ៊ុនអាកាសចរណ៍នានា និងប្រតិបត្តិការអាកាសយានដ្ឋានអន្តរជាតិ និងអាកាសយានដ្ឋានមូលដ្ឋាន ដោយគ្មានមូលហេតុស្របច្បាប់ ឬរំលោភបំពានសមត្ថកិច្ចដទៃ ត្រូវទទួលរងនូវទណ្ឌកម្មស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី១១
## អន្តរប្បញ្ញត្តិ

**មាត្រា២៣ .-**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលពាក់ព័ន្ធនឹងការតែងតាំងសមាសភាពនានាក្នុងក្របខ័ណ្ឌការងារនៃគណៈកម្មាធិការជាតិសន្តិសុខអាកាសចរណ៍ស៊ីវិល ត្រូវមានអានុភាពអនុវត្តបន្ត រហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី១២
## អវសានប្បញ្ញត្តិ

**មាត្រា២៤ .-**

អនុក្រឹត្យលេខ ២១២ អនក្រ.បក ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងសន្តិសុខអាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។ ៚

**មាត្រា២៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ២កើត ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មករា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ